ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៣៥៧.ស.ជ.ណ.ប.ស

ថ្ងៃពុធ ១១ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២០

សូមគោរពជូន
ឯកឧត្តមអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

កម្មវត្ថុ ៖ ការណែនាំ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) សម្រាប់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅខេត្តកណ្តាល

យោង ៖ - ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- លិខិតលេខ ១១៣ សជណ ប.ស្ថ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ របស់ក្រសួងបរិស្ថាន
- លិខិតលេខ ១៦៧៥ វ.ហ.ប.ស្ថ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន
- លិខិតលេខ ៦៨៥ ល.ស ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- លិខិតលេខ ៨៣៦ ល.ស ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- លិខិតលេខ ០៨៦ ល.ស ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា ក្រសួងបរិស្ថានឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) សម្រាប់គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅ លើផ្ទៃដីទំហំ ៤.៥៣៦ម៉ែត្រការ៉េ (បួនពាន់ ប្រាំរយសាមសិបប្រាំមួយ ម៉ែត្រការ៉េ) ដែលមានទីតាំងស្ថិតនៅភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ម្ចាស់គម្រោង) ដោយម្ចាស់គម្រោងត្រូវគោរពតាមកិច្ចសន្យាការពារបរិស្ថាន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** អនុវត្ត និងចាត់ចែងតាមការគួរ។
សូម **ឯកឧត្តម** ទទួលនូវការរាប់អានពីខ្ញុំ។

ឧបរដ្ឋមន្ត្រី
ប្រធានលេខាធិការ

សៅ_សុភាព

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងធនធានទឹក និងឧតុនិយម
- រដ្ឋបាលខេត្តកណ្តាល
- មន្ទីរបរិស្ថានខេត្តកណ្តាល
- ឯកសារ កាលប្បវត្តិ